# ច្បាប់ស្តីពីការប្រែប្រួលអាកាសធាតុ៖ វិធានអន្តរជាតិ និងការអនុវត្តល្អបំផុត

ដោយ Maria Cecilia T. Sicangco

អ្នកជំនាញផ្នែកការគ្រប់គ្រងពុទ្ធិ (ទីប្រឹក្សាបច្ចេកទេស)

សិក្ខាសាលាស្តីពីការផ្តល់ចំណេះដឹងផ្នែកច្បាប់ស្តីពីបញ្ហាបរិស្ថាន

ភ្នំពេញ ២១ – ២២ សីហា ២០១៧

សៀមរាប ២៤ – ២៥ សីហា ២០១៧

# មាតិកានៃបទបង្ហាញ

- វិបត្តិអាកាសធាតុ
- របបប្រែប្រួលអាកាសធាតុអន្តរជាតិដែលមានបច្ចុប្បន្ន
- ការរួមចំណែកថ្នាក់ជាតិរបស់កម្ពុជា
- ផលវិបាកនៃការប្រែប្រួលអាកាសធាតុ – ក្រុមដែលងាយរងគ្រោះ
- បណ្ដឹងវិវាទទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

# អាស៊ីនៅចំណុចកណ្ដាលនៃវិបត្តិអាកាសធាតុ

- ស្ថិតិខ្លះ៖
  - ត្រឹមឆ្នាំ២០៣០ ការបំភាយឧស្ម័នផ្ទះកញ្ចក់របស់អាស៊ី នឹងកើនឡើងដល់ ៤៥% ពី ៣១% ក្នុងឆ្នាំ២០០៧។
  - ប្រទេសចំនួន ៦ ក្នុងប្រទេសចំនួន ១០ ដែលងាយរងគ្រោះបំផុតនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (រួមមាន ហ្វីលីពីន ឥណ្ឌា កម្ពុជា ប៉ាគីស្ថាន ឡាវ និង វៀតណាម)។
  - ការប្រែប្រួលអាកាសធាតុ នឹងធ្វើឱ្យតម្លៃម្ហូបអាហារកើនឡើង ១០% ដែលជាហេតុធ្វើឱ្យមនុស្ស ៦៤ លាននាក់ ធ្លាក់ខ្លួនចូលក្នុងភាពក្រីក្រ។

# អាស៊ីនៅចំណុចកណ្តាលនៃវិបត្តិអាកាសធាតុ

- ពីឆ្នាំ១៩៧០-២០១០ – មនុស្សចំនួន ១,៧ លាននាក់ ស្លាប់ដោយសារគ្រោះថ្នាក់នៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក (៥១% នៃករណីស្លាប់សរុបក្នុងសកលលោក)
    - ការខាតបង់ប្រចាំឆ្នាំជាមធ្យមដោយសារគ្រោះមហន្តរាយ = ៥៣,៧ ពាន់លានដុល្លារ
- ៤១,២% នៃគ្រោះមហន្តរាយធម្មជាតិក្នុងពិភពលោកដែលបានរាយការណ៍ពីឆ្នាំ២០០៤ និង ២០១៣ បានកើតឡើងនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក
    - មនុស្ស ១,៥ ពាន់លាននាក់ ត្រូវបានប៉ះពាល់ ស្លាប់ជាង ៧០០.០០០នាក់

ADB









# របបនៃការប្រែប្រួលអាកាសធាតុអន្តរជាតិដែលមានបច្ចុប្បន្ន

ពិភពលោកកំពុងផ្លាស់ប្តូរវិធានការ

# អត្ថបទស្នូលនៃការប្រែប្រួលអាកាសធាតុ

## (Climate Change CORE TEXTS)

# អនុសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ឆ្នាំ១៩៩២

- គោលដៅចម្បង
  - រក្សាលំនឹងកំហាប់ឧស្ម័នផ្ទះកញ្ចក់ (GHG) "នៅក្នុងកម្រិតមួយដែលនឹងទប់ស្កាត់ការរំខានដែលបង្កឡើងដោយមនុស្សប្រកបដោយគ្រោះថ្នាក់ ដល់ប្រព័ន្ធអាកាសធាតុ": មាត្រា ២
- គោលការណ៍គន្លឹះ
  - ការទទួលខុសត្រូវរួមគ្នា ប៉ុន្តែខុសគ្នា និងសមត្ថភាពរៀងៗខ្លួន (CBDR-RC): មាត្រា ៣.១. ដូច្នេះប្រទេសអភិវឌ្ឍន៍នាំមុខគេក្នុងការប្រយុទ្ធនឹងការប្រែប្រួលអាកាសធាតុ
- ១៩៧ ភាគី
  - ឧបសម្ព័ន្ធទី I (OECD + EIT) – ធ្វើការកម្រិតការបំភាយ GHG + ការពារអាងស្រូប GHG (sinks)
  - ឧបសម្ព័ន្ធ II (OECD) – ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ភាគីជាប្រទេសកំពុងអភិវឌ្ឍន៍ (ភាគីដែលមិនស្ថិតនៅក្នុងឧបសម្ព័ន្ធទី I)

# ពិធីសារក្យូតូ ឆ្នាំ១៩៩៧ (ចាប់ផ្តើមក្នុងឆ្នាំ២០០៥)

- សម្រាប់អនុវត្ត UNFCCC
- កាតព្វកិច្ចកាត់បន្ថយការបំភាយ GHG សម្រាប់ភាគីឧបសម្ព័ន្ធទី I នៃ UNFCCC សម្រាប់រយៈពេលប្តេជ្ញាចិត្តពីរដំណាក់កាល

**រយៈពេលប្តេជ្ញាចិត្តទី 1**

2008-2012: 5% ក្រោមកម្រិត 1990 + ចំណុចដៅនីមួយៗ រៀបរាប់ក្នុងឧបសម្ព័ន្ធ B

**រយៈពេលប្តេជ្ញាចិត្តទី 2**

2013-2020: 18% ក្រោមកម្រិត 1990

# ពិធីសារក្យូតូ ឆ្នាំ១៩៩៧ (បានចាប់ផ្តើមក្នុងឆ្នាំ២០០៥)

- សមាសភាគសំខាន់ៗផ្សេងទៀត

**យន្តការផ្អែកលើទីផ្សារបត់បែន ជាមួយនីតិវិធីអភិបាលកិច្ច**

អនុញ្ញាតឱ្យពាណិជ្ជកម្មដែលបំភាយ ជំរុញការវិយោគបៃតងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍

**យន្តការអនុលោមភាព**

សម្រួល និងពង្រឹងការអនុលោមតាមការប្តេជ្ញាចិត្ត

# កិច្ចព្រមព្រៀងក្រុងប៉ារីស ឆ្នាំ២០១៥




កិច្ចព្រមព្រៀងក្រុងប៉ារីស "និរន្តរភាពភពផែនដីៗ និរន្តរភាពមនុស្សជាតិៗ និរន្តរភាពជីវិតៗ"

# គោលបំណងនៃកិច្ចព្រមព្រៀង

- *ពង្រឹងការឆ្លើយតបជាសកលទៅនឹងការប្រែប្រួលអាកាសធាតុតាមរយៈ*

| | |
|---|---|
| **សីតុណ្ហភាព** | រក្សាកំណើនសីតុណ្ហភាពសកលលោកជាមធ្យមត្រឹម "ក្រោម ២អង្សាសេ" ខាងលើកម្រិតបុរេឧស្សាហកម្ម និង "ធ្វើការខិតខំកម្រិតកំណើនសីតុណ្ហភាពត្រឹម ១,៥ អង្សាសេ...": មាត្រា 2.1(a) |
| **កម្រិតកំពូលនៃ GHG Peaking** | គោលដៅសម្រេចឱ្យបានកម្រិតកំពូលនៃការបំភាយ GHG ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន៖ មាត្រា 4(1) |
| **ការបន្សាំ** | បង្កើនលទ្ធភាពបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ និងជំរុញភាពធន់នៃការអាកាសធាតុ និងការបំភាយ GHG ទាប៖ មាត្រា 2(1)(b) |
| **ហិរញ្ញវត្ថុ** | ធ្វើឱ្យលំហូរហិរញ្ញវត្ថុស្របតាមគន្លង ឆ្ពោះទៅរកការបំភាយ GHG ទាប នឹងការអភិវឌ្ឍភាពធន់នឹងអាកាសធាតុ៖ មាត្រា 2(1)(c) |

# គោលការណ៍គន្លឹះ

"ការអភិវឌ្ឍប្រកបដោយចីរភាព និងកិច្ចខិតខំប្រឹងប្រែងដើម្បីលុបបំបាត់ភាពក្រីក្រ": មាត្រា 2(1) និង 4(1)

"សមធម៌ និងការទទួលខុសត្រូវរួមគ្នា ប៉ុន្តែខុសគ្នា និងសមត្ថភាពរៀងៗខ្លួន នៅក្នុងបរិបទជាតិខុសៗគ្នា": មាត្រា 2(2)

# សមាសធាតុសារវន្តនៃកិច្ចព្រមព្រៀង

- គោលដៅសីតុណ្ហភាពរយៈពេលវែង: មាត្រា 2
- កម្រិតកំពូលនៃការបំភាយសកល និងការរួមចំណែកដែលកំណត់ដោយថ្នាក់ជាតិ (NDCs): មាត្រា 4
- អាងស្រូប និងអាងស្តុក (Sinks and reservoirs): មាត្រា 5
- ការបន្ថយ (Mitigation) – ការផ្ទេរលទ្ធផលកាត់បន្ថយជាអន្តរជាតិ និងយន្តការអភិវឌ្ឍន៍ប្រកបដោយចីរភាព: មាត្រា 6
- គោលដៅបន្សាំ៖ មាត្រា 7
- ការបាត់បង់ និងការខូចខាត៖ មាត្រា 8
- ការគាំទ្រ – ហិរញ្ញវត្ថុ (មាត្រា 9), ការអភិវឌ្ឍនិងការផ្ទេរបច្ចេកវិទ្យា (មាត្រា 10), និងការកសាងសមត្ថភាព (មាត្រា 11)
- តម្លាភាព៖ មាត្រា 13
- ការពិនិត្យស្តុកជាសកល (stocktake): មាត្រា 14

# ការរួមចំណែកដែលកំណត់ដោយថ្នាក់ជាតិ

- គម្រោងវិធានការ (វិធានការកាត់បន្ថយក្នុងស្រុក) ដែលភាគីមានបំណងសម្រេចឱ្យបានដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ
- ត្រូវតែ
  - ✓ មានមហិច្ឆតា និងកំណត់សំដៅសម្រេចឱ្យបានគោលបំណងនៃកិច្ចព្រមព្រៀង៖ មាត្រា 3
  - ✓ ចុះបញ្ជីដោយលេខាធិការដ្ឋាន UNFCCC
  - ✓ រាយការណ៍រៀងរាល់ ៥ឆ្នាំម្តង៖ មាត្រា 4(9)
  - ✓ បង្ហាញពីវឌ្ឍនភាពតាមពេលវេលា – មានន័យថា NDC ជាបន្តបន្ទាប់នីមួយៗ គួរតែមានលក្ខណៈមហិច្ឆតាជាង NDC ចុងក្រោយ៖ មាត្រា 3 និង 9(3)
- មិនជាប់កាតព្វកិច្ច

# ការរួមចំណែកដែលកំណត់ដោយថ្នាក់ជាតិរបស់កម្ពុជា

# គោលនយោបាយរបស់កម្ពុជាស្តីពីការប្រែប្រួលអាកាសធាតុ

- កម្ពុជាគឺជាប្រទេសបំភាយកម្រិតទាបមួយ និងជាប្រទេសដែលងាយរងគ្រោះយ៉ាងខ្លាំងចំពោះផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ
- ផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុរបស់កម្ពុជា (CCCSP) (២០១៤ – ២០២៣)
  - រយៈពេលខ្លី (២០១៣-២០១៤)៖ ការរៀបចំផ្នែកស្ថាប័ននិងហិរញ្ញវត្ថុ ការត្រួតពិនិត្យតាមដាននិងវាយតម្លៃថ្នាក់ជាតិ និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ
  - រយៈពេលមធ្យម (២០១៣-២០១៨)៖ កម្មវិធីដែលមានអាទិភាពខ្ពស់ស្តីពីការបន្សាំ និងកំណើនសន្សើមៗនៅក្នុងវិធានការកាត់បន្ថយ និងការទទួលស្គាល់ជាផ្លូវការនូវមូលនិធិបន្សាំ និងមូលនិធិអាកាសធាតុបៃតង
  - រយៈពេលវែង (២០១៩-២០២៣)៖ ការស្រាវជ្រាវ និងការសិក្សា ការពង្រីកគំនិតផ្តួចផ្តើមដោយជោគជ័យ និងដើម្បីបញ្ច្រាបការប្រែប្រួលអាកាសធាតុ
- នាយកដ្ឋានប្រែប្រួលអាកាសធាតុដែលមានស្រាប់
  - អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិសម្រាប់ការអភិវឌ្ឍដោយចីរភាព

# ការរួមចំណែកដែលកំណត់ដោយថ្នាក់ជាតិ

- សកម្មភាពជាអាទិភាពនៃការបន្សាំ រួមមាន៖
  - សកម្មភាពបន្សាំនៅតាមសហគមន៍
  - ការពង្រឹងប្រព័ន្ធជូនដំណឹងជាមុន និងការផ្សព្វផ្សាយព័ត៌មាន
  - ទំនប់ការពារទឹកជំនន់ និងទំនប់សមុទ្រ
  - ប្រព័ន្ធកសិកម្មដែលធន់នឹងអាកាសធាតុ
  - ការពង្រឹងសមត្ថភាពបច្ចេកទេស និងស្ថាប័ន
- ចំណុចដៅនៃការកាត់បន្ថយ និងសកម្មភាពជាអាទិភាព រួមមាន៖
  - បង្កើនគម្របព្រៃឈើ ដល់ ៦០% ត្រឹមឆ្នាំ ២០៣០
  - កាត់បន្ថយការបំភាយពីឧស្សាហកម្ម ចំនួន 3,100 Gigatinnes CO2 សមមូល (Gg CO2eq) ប្រៀបធៀបនឹងទិន្នន័យគោល 11,600 Gg CO2eq ត្រឹ

# ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើក្រុមដែលងាយរងគ្រោះ

ផលប៉ះពាល់លើក្រុមដែលងាយរងគ្រោះ

# ផលប៉ះពាល់នៃអាកាសធាតុ៖ ការរំលោភសិទ្ធ

- សិទ្ធិក្នុងការរស់នៅ
- សិទ្ធិក្នុងការទទួលបានសុខភាព
- សិទ្ធិក្នុងក្នុងការទទួលបានលំនៅស្ថាន
- សិទ្ធិក្នុងទទួលបានចំណីអាហារ
- សិទ្ធិក្នុងការទទួលទឹក
- សិទ្ធិក្នុងដកដង្ហើមខ្យល់ស្អាត
- សិទ្ធិក្នុងការទទួលបានអនាម័យ
- សិទ្ធិក្នុងក្នុងការទទួលបានទ្រព្យសម្បត្តិ
- សិទ្ធិស្វ័យសម្រេចចិត្ត

# "អ្នកដែលងាយរងគ្រោះ ទទួលរងផលប៉ះពាល់មុនគេ និងអាក្រក់ជាងគេ" – លោក បាន គីមូន (Ban Ki Moon)

- ស្ត្រី
- កុមារ
- មនុស្សចាស់ និងជនពិការ
- ប្រជាជនដើមភាគតិច ឬជនក្រីក្រវេទនាតោកយ៉ាក

*ស្ត្រី និងកុមារ ទំនងជាស្លាប់ បរបួស ១៤ដងលើសបុរស ក្នុងអំឡុងពេលគ្រោះមហន្តរាយ*

# បណ្ដឹងវិវាទទាក់ទងនឹងការប្រែប្រួលអាកាសធាតុ

# តើចៅក្រមអាចធ្វើអ្វីខ្លះដើម្បីកាត់បន្ថយផលប៉ះពាល់?

- ការទទួលបានយុត្តិធម៌៖
  - ការឆ្លើយតបជាបុរេសកម្មរបស់ចៅក្រម នឹងជួយសម្រួលដល់អ្នកដែលងាយរងគ្រោះបំផុត
- ការឆ្លើយតបរបស់តុលាការ
  - សាមញ្ញដូចគ្នានឹង៖
    - ការពិគ្រោះយោបល់ EIA
    - បញ្ហាចេញអាជ្ញាប័ណ្ណ
    - បញ្ហាកម្មសិទ្ធិដីធ្លី
  - សាំញ៉ាំដូចគ្នានឹង៖
    - ការទាមទារស្ថានភាពជនភៀសខ្លួន
    - សិទ្ធិមនុស្ស - សិទ្ធិក្នុងការទទួលបានអធិបតេយ្យភាព សិទ្ធិក្នុងការបន្ត

# Ashgar Leghari v. សហព័ន្ធប៉ាគីស្ថាន (២០១៥) ញត្តិបញ្ហា (Writ Petition) លេខ 25501/201

- អ្នកដាក់ញត្តិ ដែលជាកសិករម្នាក់ បានទៅកាន់តុលាការ ដើម្បីបង្ខំឱ្យរដ្ឋាភិបាល ចាត់វិធានការលើការប្រែប្រួលអាកាសធាតុ (អនុវត្តគោលនយោបាយរបស់ខ្លួន ដោយសារតែបញ្ហានេះធ្វើឱ្យប៉ះពាល់ដល់ការប្រកបរបរកសិកម្មរបស់គាត់)
- ផ្អែកលើគោលការណ៍ច្បាប់ក្នុងស្រុកនិងអន្តរជាតិ តុលាការជាន់ខ្ពស់ក្រុងឡាហ៊រ បានសម្រេចថា "ការពន្យារពេល និងការមិនយកចិត្តទុកដាក់របស់រដ្ឋនៅក្នុងការអនុវត្តក្របខ័ណ្ឌ [សម្រាប់ការអនុវត្តគោលនយោបាយប្រែប្រួលអាកាសធាតុ] ធ្វើឱ្យប៉ះពាល់ដល់សិទ្ធិជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ។"
- តុលាការបានបង្កើតគណៈកម្មការប្រែប្រួលអាកាសធាតុមួយដើម្បីតាមដានមើលការអនុវត្តរបស់រដ្ឋាភិបាល

50 YEARS ADB

# Juliana v សហរដ្ឋអាមេរិក (6:15-cv-0517-TC) – រងចាំការប្តឹងផ្ទាស

- សំណុំរឿងដែលបានដាក់ដោយដើមចោទ២១នាក់ មកពីទូទាំងប្រទេសអាមេរិក មានអាយុពី ៨ ដល់ ១៩ឆ្នាំ
- អះអាង៖ ថារដ្ឋាភិបាលកំពុងតែបង្ក ឬរួមចំណែកយ៉ាងខ្លាំងដល់កំហាប់ដ៏គ្រោះថ្នាក់នៃ CO2 នៅក្នុងបរិយាកាស ដែលធ្វើឱ្យប៉ះពាល់ប្រកបដោយគ្រោះថ្នាក់ដល់ស្ថិរភាពអាកាសធាតុ។
  - ស្វែងរកការសង្គ្រោះ៖ សម្រាប់រដ្ឋាភិបាលរៀបចំ និងអនុវត្តផែនការដោះស្រាយជាតិដើម្បីលុបបំបាត់ការបំភាយប្រេងឥន្ធនៈផូស៊ីល និងកាត់បន្ថយឧស្ម័នកាបូនិកដែលមានកម្រិតលើសក្នុងបរិយាកាស។
- លើកឡើងដោយឈរលើមូលដ្ឋានសមធម៌អន្តរជំនាន់
- ចៅក្រមអនុញ្ញាតឱ្យដាក់ញត្តិ ដោយបញ្ជាក់ថា៖ សិទ្ធិក្នុងការទទួលបានប្រព័ន្ធអាកាសធាតុមួយដែលមានសមត្ថភាពទ្រទ្រង់ជីវិតមនុស្ស គឺជាមូលដ្ឋានគ្រឹះនៃសង្គមមួយដែលសេរីនិងមានសណ្តាប់ធ្នាប់